# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

## សេចក្តីប្រកាសព័ត៌មាន

**ក្រសួងយុត្តិធម៌** មានកិត្តិយសសូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ កន្លងទៅ, ក្រសួងយុត្តិធម៌ បានអញ្ជើញគណបក្សនយោបាយ និងអង្គការសង្គមស៊ីវិល ដែលយល់ថា ឬអះអាងថា ការធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ប៉ះពាល់ដល់**របបប្រជាធិបតេយ្យសេរីពហុបក្ស** និង**របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ** ឬ**របបសភានិយម** ដើម្បីមកជួបពិភាក្សាតទល់មុខគ្នាដោយផ្ទាល់ នៅចំពោះមុខមហាជន តាមរយៈការផ្សាយផ្ទាល់តាមបណ្តាញសារព័ត៌មាន សំដៅជម្រះចោលនូវកង្វល់មិនត្រឹមត្រូវនានា ជុំវិញការធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនេះ។ ប៉ុន្តែរហូតមកដល់ពេលនេះ គណបក្សនយោបាយទាំង ៤ ដែលបានដាក់ញត្តិជូនទៅរដ្ឋសភា ជំទាស់នឹងការធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនេះ និងអង្គការសង្គមស៊ីវិលចំនួន ១០៤ ដែលបានចេញសេចក្តី-ថ្លែងការណ៍សម្តែងនូវកង្វល់នានា ជុំវិញការធ្វើវិសោធនកម្មនេះ ពុំបានអញ្ជើញចូលរួមតាមការអញ្ជើញរបស់ក្រសួងយុត្តិធម៌នោះទេ។

**ក្រសួងយុត្តិធម៌** ពិនិត្យឃើញថា ប្រសិនបើគណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលទាំងនោះ ពិតជាមានបំណងដោយសុទ្ធចិត្ត ដើម្បីចង់ការពារ**រដ្ឋធម្មនុញ្ញ**, **របបប្រជាធិបតេយ្យសេរីពហុបក្ស**, **របបរាជា-និយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ** ឬ**របបសភានិយម** ដូចអ្វីដែលបានអះអាងពិតប្រាកដមែននោះ, គួរណាស់តែតំណាងគណបក្សនយោបាយ ឬតំណាងអង្គការសង្គមស៊ីវិលទាំងនោះ អញ្ជើញតាមការអញ្ជើញរបស់ក្រសួងយុត្តិធម៌ ដើម្បីស្វែងយល់ឱ្យបានត្រឹមត្រូវអំពីខ្លឹមសារ និងគោលបំណងពិតប្រាកដនៃការធ្វើវិសោធនកម្មលើកទី១០ នេះ ឬដើម្បីលើកយកទឡ្ហីករណ៍មកតទល់ពន្យល់គ្នាទៅវិញទៅមកជាមួយក្រសួងយុត្តិធម៌ ដោយមានការផ្សាយផ្ទាល់តាមបណ្តាញសារព័ត៌មាន ដើម្បីអាចឱ្យសាធារណជន អាចយល់ច្បាស់ថា តើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ នេះ ពិតជាបានប៉ះពាល់ដល់**របបប្រជាធិបតេយ្យសេរីពហុបក្ស** ឬ**របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ** ឬ**របបសភានិយម** ដូចអ្វីដែលគណបក្សនយោបាយទាំង ៤ ឬ អង្គការសង្គមស៊ីវិលទាំង ១០៤ បានលើកឡើងនោះដែរ ឬទេ?

**ក្រសួងយុត្តិធម៌** មានការសោកស្តាយដោយគណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលខាងលើ មិនបានចូលរួមតាមការអញ្ជើញខាងលើនេះ ក្រោមលេសនានាដោយមិនសមហេតុផល។



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

**ក្រសួងយុត្តិធម៌** សង្ឃឹមថា តាមរយៈការបកស្រាយបំភ្លឺជាបន្តបន្ទាប់របស់តំណាងរាជរដ្ឋាភិបាល, គណបក្សនយោបាយទាំង ៤ និងអង្គការសង្គមស៊ីវិលទាំង ១០៤ ពិតជាអាចទទួលយកនូវការពន្យល់បកស្រាយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាលអំពីខ្លឹមសារ និងគោលបំណងពិតប្រាកដនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ។

**ក្រសួងយុត្តិធម៌** សូមបញ្ជាក់ជូនថា សេចក្ដីព្រាងច្បាប់ធម្មនុញ្ញស្ដីពីការធ្វើវិសោធនកម្មលើកទី១០ នេះ ត្រូវបាន**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** សម្រេចអនុម័តដោយមតិភាគច្រើនលើសពីពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០២២ ហើយ**ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** ក៏បានសម្រេចផ្ដល់យោបល់យល់ព្រមទាំងស្រុងលើទម្រង់ច្បាប់ និងគតិច្បាប់ដោយឥតកែប្រែដោយមតិភាគច្រើនលើសពីពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល នាសម័យប្រជុំលើកទី៩ នីតិកាលទី៤ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ នេះ។ ជានីតិវិធីបន្ត, ច្បាប់ធម្មនុញ្ញនេះ នឹងត្រូវថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** *នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃប្រជាជាតិខ្មែរ* ដើម្បីទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ដែលជានីតិវិធីចុងក្រោយនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដោយអនុលោមទៅតាមនីតិវិធីជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ក្រោយនីតិវិធីទាំងនេះបានចប់សព្វគ្រប់, រដ្ឋធម្មនុញ្ញក្រោយវិសោធនកម្មនេះ នឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ជាតិ ដើម្បីធានាការពារឧត្ដមប្រយោជន៍របស់ជាតិ និងប្រជាជនកម្ពុជា ហើយទាំងប្រជាជនកម្ពុជា ទាំងគណបក្សនយោបាយទាំងអស់ដែលទទួលបានការបោះឆ្នោតគាំទ្រពីសំណាក់ប្រជាជនកម្ពុជា នឹងទទួលបានអត្ថប្រយោជន៍ពីភាពមិនជាប់គាំង និងកិច្ចដំណើរការដោយរលូន និងប្រកបដោយនិរន្តរភាពនៃស្ថាប័នកំពូលរបស់ជាតិ ពិសេស ស្ថាប័ននីតិប្រតិបត្តិ ដែលមានបេសកកម្មដឹកនាំការងារទូទៅរបស់ជាតិ។

ថ្ងៃសុក្រ ៨កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២